# ពង្រឹងច្បាប់ដើម្បីដោះស្រាយការកេងប្រវ័ញ្ចបុគ្គលិកអន្តោប្រវេសន

## សង្ខេប

រដ្ឋាភិបាលអូស្ត្រាលីកំពុងពង្រឹងច្បាប់ដើម្បីដោះស្រាយការកេងប្រវ័ញ្ចកម្មករអន្តោប្រវេសន៍ ការកែទម្រង់ផ្សេងៗដែលអនុម័តដោយរដ្ឋសភាគឺជាផ្នែកមួយនៃកញ្ចប់ដ៏ទូលំទូលាយនៃការកែទម្រង់ដើម្បីលើកកម្ពស់ការគោរពតាមច្បាប់របស់និយោជក និងការការពារនិយោជិត។

ច្បាប់ថ្មីៗនឹងចាប់ផ្តើមនៅថ្ងៃទី 1 កក្កដា 2024 ហើយនឹងត្រូវអនុវត្តទាំងទៅលើនិយោជកផ្ទាល់ និងអ្នកផ្សេងទៀតនៅក្នុងសង្វាក់ផ្គត់ផ្គង់បុគ្គលិកដូចជាក្រុមហ៊ុនផ្គត់ផ្គង់បុគ្គលិកផ្សេងៗជាដើម។ វិធានការផ្សេងៗក្រោមច្បាប់ស្តីពីការពង្រឹងការគោរពច្បាប់របស់និយោជកនឹង ៖

- ពង្រឹងច្បាប់ផ្សេងៗដើម្បីការពារកម្មករអន្តោប្រវេសន៍ពីការកេងប្រវ័ញ្ចលើកម្មករ
- លើកកម្ពស់ការគោរពច្បាប់របស់និយោជកដោយប្រើទាំងរនាំង និងការកែតម្រូវផ្សេងៗ
- ជួយដើម្បីធានាថានិយោជកដែលគោរពតាមច្បាប់ទាំងឡាយនឹងមិនរងគ្រោះដោយអ្នកប្រកួតប្រជែងមិនស្មោះត្រង់នោះទេ។

## វិធានការផ្សេងៗ

វិធានការសំខាន់ៗរួមបញ្ចូលក្រោមការកែប្រែច្បាប់អន្តោប្រវេសន៍រួមមាន ៖

- បទល្មើសឧក្រិដ្ឋ និងការផាកពិន័យថ្មីចំពោះការប្រើប្រាស់ឋានៈអន្តោប្រវេសន៍របស់ជនណាមួយដើម្បីកេងប្រវ័ញ្ចពួកគេនៅកន្លែងការងារ។ បទល្មើសទាំងនេះរងនូវការពិន័យឧក្រិដ្ឋដោយជាប់ពន្ធនាគារ 2ឆ្នាំ និង/ឬ ផាកពិន័យ 360 ឯកតាផាកពិន័យ (បច្ចុប្បន្ននេះពិន័យ $118,800) ឬការផាកពិន័យស៊ីវិលចំនួន 240 ឯកតាពិន័យ (បច្ចុប្បន្ននេះពិន័យ $79,200)។
- វិធានការហាមឃាត់ថ្មី - និយោជកទាំងឡាយណាដែលជាប់ទាក់ទងនឹងការកេងប្រវ័ញ្ចធ្ងន់ធ្ងរ ដោយចេតនា ឬម្តងហើយម្តងទៀតលើកម្មករអន្តោប្រវេសន៍នឹងត្រូវហាមឃាត់មិនឲ្យជួលបុគ្គលិកអន្តោប្រវេសន៍បន្ថែមក្នុងមួយរយៈពេលអាស្រ័យទៅលើប្រភេទ និងភាពធ្ងន់ធ្ងរនៃការរំលោភច្បាប់។ និយោជកទាំងឡាយដែលរងការហាមឃាត់នឹងត្រូវរៀបរាប់ក្នុងបញ្ជី លើគេហទំព័រកងកម្លាំងព្រំដែនអូស្ត្រាលី ហើយនឹងត្រូវតម្រូវឲ្យរាយការណ៍បន្ថែមទៀតបន្ទាប់ពីការហាមឃាត់ចប់។ អ្នកអាចរងនូវការកាត់ទោសប្រសិនបើអ្នករំលោភលើបម្រាម ឧទាហរណ៍ ការជួលអ្នកកាន់ទិដ្ឋាការបណ្តោះអាសន្នទៀតក្នុងអំឡុងពេលហាមឃាត់។
- ឧបករណ៍ថ្មីៗ - សេចក្តីជូនដំណឹងពីការគោរពតាមច្បាប់ និងសមត្ថភាពក្នុងចូលរួម ការសន្យាដែលអាចអនុវត្តបាននឹងជួយនិយោជកទាំងឡាយឲ្យយល់ និងបំពេញឲ្យបាននូវកាតព្វកិច្ចរបស់ខ្លួនដោយគ្មានការបង់ពិន័យ (ប្រសិនបើសមស្រប)។
- ការការពារកាន់តែប្រសើរដល់បុគ្គលិកអន្តោប្រវេសន៍បណ្តោះអាសន្នដើម្បីលើកទឹកចិត្តដល់ការរាយការណ៍។

## ការទទួលខុសត្រូវរបស់និយោជក

និយោជកទាំងឡាយទទួលខុសត្រូវក្នុងការធានាថាអ្នកកាន់ទិដ្ឋាការបណ្តោះអាសន្នមានទិដ្ឋាការមានសុពលភាព ហើយមិនរំលោភលក្ខខណ្ឌផ្សេងៗក្នុងទិដ្ឋាការរបស់គេ។ ពិនិត្យមើលលក្ខខណ្ឌផ្សេងៗរបស់បុគ្គលិកនៅ ការផ្ទៀងផ្ទាត់ និងបញ្ជាក់លក្ខខណ្ឌទិដ្ឋាការតាមអនឡាញ។

ពួកគេក៏ត្រូវតែគោរពតាមច្បាប់កន្លែងបំពេញការងាររួមមាន ការបង់ប្រាក់ឈ្នួលអប្បរមា, ច្បាប់ស្តីពីការបង់ប្រាក់សោធននិវត្តន៍ និង លក្ខខណ្ឌសុខភាព និងសុវត្ថិភាព។

សិទ្ធិបុគ្គលិកអន្តោប្រវេសន៍

ច្បាប់កេងប្រវ័ញ្ចបុគ្គលិកអន្តោប្រវេសន៍ថ្មី

ការផ្ទៀងផ្ទាត់ និងបញ្ជាក់លក្ខខណ្ឌទិដ្ឋាការតាមអនឡាញ

គណៈកម្មាធិការយុត្តិធម៌កន្លែងការងារ (Fair Work Ombudsman)